**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

គាំពារសង្គមកម្ពុជា
SOCIAL PROTECTION IN CAMBODIA

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីជូនដំណឹង
## ស្តីពី
## ការបើកផ្តល់ប្រាក់ឧបត្ថម្ភជូនបងប្អូនកម្មករនិយោជិតក្នុងវិស័យកាត់ដេរ និងទេសចរណ៍ ដែលត្រូវបានព្យួរកិច្ចសន្យាការងារស្របតាមស្មារតីនៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាល (លើកទី៥២)

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់បងប្អូនកម្មករនិយោជិតចំនួន ៦ ៣៥៦ នាក់ នៃរោងចក្រ សហគ្រាស ទាំង៣១ នៃវិស័យកាត់ដេរ និងវិស័យទេសចរណ៍ (ដូចមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ) ដែលទទួលបានការអនុញ្ញាតព្យួរកិច្ចសន្យាការងារស្របតាមស្មារតីជុំទី៣នៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាលជ្រាបថា ធនាគារឯកទេសវីង នឹងផ្ញើសារអំពីការបើកប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលទៅលេខទូរសព្ទ ដែលបងប្អូនបានផ្តល់មកឱ្យក្រសួងតាមរយៈរដ្ឋបាលរោងចក្រ សហគ្រាសនាពេលកន្លងមក។

ប្រាក់ឧបត្ថម្ភនេះនឹងត្រូវបើកផ្តល់ជាប្រាក់រៀល និងអាស្រ័យលើចំនួនថ្ងៃនៃការព្យួរកិច្ចសន្យាការងារ ក្នុងនោះចំនួន៖

- ១២១ ៥០០រៀល (៣០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ១១ថ្ងៃ ដល់ ២០ថ្ងៃ
- ១៦២ ០០០រៀល (៤០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេលចាប់ពី ២១ថ្ងៃ ដល់ ១ខែ។ សូមបញ្ជាក់ថា សម្រាប់បងប្អូនដែលព្យួរកិច្ចសន្យាការងាររយៈពេល ២ខែ ប្រាក់ឧបត្ថម្ភនឹងត្រូវបើកជា ២លើក ដោយលើកទី២ នឹងបើកនៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២១។

ក្រសួងសូមរំឭកថា ធនាគារឯកទេសវីង នឹងបង្វិលប្រាក់ឧបត្ថម្ភនេះជូនរាជរដ្ឋាភិបាលវិញ ប្រសិនជាបងប្អូនខកខានមិនបានទៅបើកប្រាក់ឧបត្ថម្ភនេះ ក្នុងរយៈពេល ១០ថ្ងៃ បន្ទាប់ពីទទួលបានសារតាមទូរសព្ទពីធនាគារឯកទេសវីង។ ដើម្បីបើកប្រាក់ឧបត្ថម្ភនេះ បងប្អូនត្រូវយកអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងទូរសព្ទដែលទទួលបានសារនោះទៅកាន់ភ្នាក់ងារវីងដែលនៅជិតបំផុត។ សូមបញ្ជាក់ថា បងប្អូនមិនតម្រូវឱ្យបង់ថ្លៃសេវាទៅភ្នាក់ងារវីងឡើយពេលបើកប្រាក់ឧបត្ថម្ភនេះ។

ក្នុងករណីបងប្អូនកម្មករនិយោជិត ដែលបម្រើការងារនៅរោងចក្រ សហគ្រាស ទាំង៣១ នេះ មិនបានទទួលសារទូរសព្ទពីធនាគារឯកទេសវីង នោះសូមបងប្អូនទំនាក់ទំនងសួរព័ត៌មានបន្ថែម ឬធ្វើបច្ចុប្បន្នភាពលេខទូរសព្ទរបស់ខ្លួន ទៅរដ្ឋបាលរោងចក្រ សហគ្រាសរបស់ខ្លួន។ ក្រសួងនឹងបន្តជូនដំណឹងដល់បងប្អូនកម្មកររោងចក្រ សហគ្រាសដទៃផ្សេងទៀតអំពីការបើកផ្តល់ប្រាក់ឧបត្ថម្ភនេះ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម សាធារណជន ជាពិសេសបងប្អូនកម្មករនិយោជិតជ្រាបជាព័ត៌មាន និងសូមរួសរាន់ទំនាក់ទំនងបើកប្រាក់ឧបត្ថម្ភនេះនៅតាមភ្នាក់ងារវីងនានាដែលនៅជិតបំផុតឱ្យបានទាន់ពេលវេលា។

*ថ្ងៃ ព្រហស្បតិ៍ ៦រោច ខែ ផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤*

*រាជធានីភ្នំពេញ ថ្ងៃទី ៤ ខែ មីនា ឆ្នាំ២០២១*

*អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣) ៨៨ ៤៣ ៧៥ និងទូរសារ :(០២៣) ៨៨ ២៧ ៦៩*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**គណៈកម្មការអនុវត្តវិធានការរាជរដ្ឋាភិបាល**

**ឧបសម្ព័ន្ធ នៃសេចក្តីជូនដំណឹងចុះថ្ងៃទី៤ ខែមីនា ឆ្នាំ២០២១**

**បញ្ជីឈ្មោះ រោងចក្រ សហគ្រាស ក្នុងវិស័យកាត់ដេរ និងវិស័យទេសចរណ៍**
**ចំនួន ៣១ ដែលទទួលបានប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល**

| ល.រ | ឈ្មោះរោងចក្រ សហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| ក. វិស័យកាត់ដេរ | | 14 |
| 1 | ក្រុមហ៊ុន ខ្វាន់ទុម ខ្លូស៊ីង (ខេមបូឌា) លីមីតធីត | ភ្នំពេញ |
| 2 | ក្រុមហ៊ុន ខាយ & ខាយវើលដ៍ | ភ្នំពេញ |
| 3 | ក្រុមហ៊ុន យ៉ង់ ស៊ឹង | កណ្តាល |
| 4 | ក្រុមហ៊ុន អ៊ី ហ្គាមេន ខូអិលធីឌី | កណ្តាល |
| 5 | ក្រុមហ៊ុន ហ្សុងហ្វ័រយុនជីន (ខេមបូឌា) ហ្គាមេនខូអិល ធីឌី | កំពង់ស្ពឺ |
| 6 | ក្រុមហ៊ុន អ៊ែដ្យាយល៍ ស្វេតធី (ខេមបូឌា) ខូអិលធីឌី | កំពង់ស្ពឺ |
| 7 | ក្រុមហ៊ុន ជាតធេច(ខេមបូឌា)ឯ.ក | កំពង់ស្ពឺ |
| 8 | ក្រុមហ៊ុន វីនតាយ សកខ៍ មេនូហ្វេឈ័រ អិលធីឌី | តាកែវ |
| 9 | ក្រុមហ៊ុន ណាញ ស្គាយ ហ្គាម៉ិន ឯ.ក | តាកែវ |
| 10 | ក្រុមហ៊ុន ដាតាន់ អ៊ិនដាសស្ទ្រៀល ឯ ក ស្រុកព្រៃឈរ ខេត្តកំពង់ចាម | កំពង់ចាម |
| 11 | ក្រុមហ៊ុន អរិន មេនូហ្វេកឆឺរីង ( ខ្មែរ ) | ព្រៃវែង |
| 12 | ក្រុមហ៊ុន ថប ស៊ីលវើរ លីមីធីត | ព្រៃវែង |
| 13 | ក្រុមហ៊ុន ហ៊ែលសា សៅអ៊ិសអេស៊ា ខូអិលលធីឌី | ស្វាយរៀង |
| 14 | ក្រុមហ៊ុន អិម ជេ ប៉ែក (ខេមបូឌា) ខូអិលធីឌី | ព្រះសីហនុ |
| ខ. វិស័យទេសចរណ៍ | | 17 |
| 15 | ក្រុមហ៊ុន កាំបូឌីយ៉ាណា អ៊ិនវេស្តមេនធ៍ (ភ្នំពេញ) ភីធីអ៊ី អែលធីឌី | ភ្នំពេញ |
| 16 | ក្រុមហ៊ុន សិប្បករអង្គរ ភ្នំពេញ | ភ្នំពេញ |

| ល.រ | ឈ្មោះភោជនីយដ្ឋាន សហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| 17 | ក្រុមហ៊ុន ស្កាយ យីង ត្រាវែល & ធួរ | ភ្នំពេញ |
| 18 | ក្រុមហ៊ុន គូបេ យៃតែននីស វែស្ទវែន | សៀមរាប |
| 19 | សណ្ឋាគារសុខាល័យអង្គរ រីហ្សត និងស្ប៉ា | សៀមរាប |
| 20 | ក្រុមហ៊ុន សិប្បករអង្គរ | សៀមរាប |
| 21 | ក្រុមហ៊ុន វេសធីវេន ខូឡិចហ្សិន | សៀមរាប |
| 22 | សណ្ឋាគារ អង្គរ ហូតែល គ្រុប(សណ្ឋាគារ អប្សរា ផាឡេស) | សៀមរាប |
| 23 | សណ្ឋាគារ សាឯមសៀមរាប | សៀមរាប |
| 24 | ក្រុមហ៊ុន ហ្គោថូន ត្រាវែល សឺវីស | សៀមរាប |
| 25 | ក្រុមហ៊ុន កាឡាស ខម(ខេមបូឌា)ភីធីអ៊ីអិលធីឌី (សណ្ឋាគារ អង្គរ អេរ៉) | សៀមរាប |
| 26 | ក្រុមហ៊ុន ដំណាក់យៃភីថល ឯ.ក | សៀមរាប |
| 27 | សណ្ឋាគារគោព្រៃ | សៀមរាប |
| 28 | ក្រុមហ៊ុន តារារង្សី អង្គរ ហូថេល | សៀមរាប |
| 29 | ផ្ទះសំណាក់ សាតូអង្គរ | សៀមរាប |
| 30 | សណ្ឋាគារសោមាទេវីអង្គររីសត & ស្ប៉ា | សៀមរាប |
| 31 | ក្រុមហ៊ុន អានឡុង អេហ្សេត អ៊ិនវេសមេន | សៀមរាប |